**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**


**ប្រធានគណៈមេធាវី**

មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង វណ្ណះ

២-មេធាវី អ៊ុំ គិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ីវ ប៉ូលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុកន្ធូន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈីវ គិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មាននួ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី យឹម វិសុត្ត

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហូ លីហូវ

២៣-មេធាវី វ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ: ០១៤ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៦

# សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងអធិការនៃនាយកដ្ឋានអធិការកិច្ចគណៈមេធាវី

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្ដីសម្រេចលេខ ០០១/សសគម/១៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ របស់គណៈមេធាវី ស្ដីពីការតែងតាំងអធិការនៃនាយកដ្ឋានអធិការកិច្ចគណៈមេធាវី
- បានឃើញសំណើរបស់សាមីខ្លួន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦។

## ស ម្រេ ច

**ប្រការ ១.-** តែងតាំងលោកមេធាវី **ខៀវ តុលា** អត្តលេខ **៨៥៤** និងលោកមេធាវី **សេង-ឈុនលី** អត្តលេខ **៧៩២** ជាអធិការនៃនាយកដ្ឋានអធិការកិច្ចគណៈមេធាវី។៕


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨

ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

**ប្រការ ២.-** លោកមេធាវី **ខៀវ តុលា** និងលោកមេធាវី **សេង ឈុនលី** មានភារកិច្ចដូចខាងក្រោម ៖

-ពិនិត្យ តាមដាន លើគ្រប់សកម្មភាពរំលោភលើវិធានវិជ្ជាជីវៈមេធាវី ពីសំណាក់សមាជិក-សមាជិកាគណៈមេធាវី និងពីសំណាក់បុគ្គលដទៃទៀត តាមការចាត់តាំងរបស់ប្រធានគណៈ-មេធាវី

-ត្រូវរាយការណ៍ជាសម្ងាត់ ឬ ជាលាយលក្ខណ៍អក្សរ ភ្ជាប់ដោយភស្តុតាងមកប្រធានគណៈ-មេធាវី ដើម្បីដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច

-ទទួលភារកិច្ចផ្សេងៗទៀត ដែលត្រូវបានចាត់តាំងដោយប្រធានគណៈមេធាវី ។

**ប្រការ ៣.-** លោកមេធាវី **ខៀវ តុលា** និងលោកមេធាវី **សេង ឈុនលី** ត្រូវទទួលខុសត្រូវចំពោះមុខប្រធាន និងក្រុមប្រឹក្សាគណៈមេធាវីលើសកម្មភាព និងលទ្ធផលការងាររបស់ខ្លួន ។

**ប្រការ ៤.-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក ប្រធាននាយកដ្ឋានអធិការកិច្ច និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ៕

**មេធាវី. ប៊ុន-ហុន**

**ចម្លងជូន :**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

*"ដើម្បីជូនជ្រាប"*

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: ១៤០
-ម៉ោង: ១០.០០
-ថ្ងៃ ខែ ឆ្នាំ: ២១.០១.១៦
-បញ្ជូន:

# ពាក្យសុំ

ខ្ញុំបាទមេធាវី **ខៀវ គុណា** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ការិយាល័យផ្ទះលេខ៤៩E0 ផ្លូវ៣៣៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## សូមគោរពជូន

### លោកប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ:** សំណើសុំចូលជាសមាជិកក្រុមអធិការកិច្ច នៃនាយកដ្ឋានអធិការកិច្ចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូន **លោកប្រធាន** ប្រធានមេត្តាជ្រាបថា ខ្ញុំបាទជាមេធាវីពេញសិទ្ធិតាំងពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤មានអត្តលេខ៨៥៤ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាហើយកំពុងប្រកបវិជ្ជាជីវៈមេធាវីនៅការិយាល័យក្រុមហ៊ុនមេធាវី អិល អេស ភី (LSP LAW FIRM) ។ក្នុងគោលបំណងរួមចំណែកពង្រឹងនិងលើកស្ទួយវិជ្ជាជីវៈមេធាវី ខ្ញុំបាទពិតជាមានពេលវេលាគ្រប់គ្រាន់និងឆន្ទៈក្នុងការជួយបំរើការងារនៅក្នុងនាយកដ្ឋានអធិការកិច្ចរបស់ គណៈមេធាវី តាមការចាត់តាំងរបស់ប្រធានគណៈមេធាវីឬប្រធាននាយកដ្ឋានអធិការកិច្ច។

អាស្រ័យដូចបានជំរាបជូនខាងលើសូម **លោកប្រធាន** មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

សូម**លោកប្រធាន**មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ភ្នំពេញ.ថ្ងៃទី២០ខែមករា ឆ្នាំ២០១៦

**ហត្ថលេខានិងត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី. ខៀវ គុណា

21/01/16

ប៊ុន ណារីណា

22-01-16

មេធាវី. ប៊ុន_ហុន

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: ១៩១
-ម៉ោង: ១០.០០
-ថ្ងៃ ខែ ឆ្នាំ: ២១.០១.១៦
-បញ្ជូន:

## ពាក្យសុំ

ខ្ញុំបាទមេធាវី **សេង ឈុនលី** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាការិយាល័យផ្ទះលេខ២២C ផ្លូវ៣៧១សង្កាត់ទឹកថ្លាខណ្ឌសែនសុខ រាជធានីភ្នំពេញ។

## សូមគោរពជូន

### លោកប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ:** សំណើសុំចូលជាសមាជិកក្រុមអធិការកិច្ច នៃនាយកដ្ឋានអធិការកិច្ចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូន **លោកប្រធាន** ប្រធានមេត្តាជ្រាបថា ខ្ញុំបាទជាមេធាវីពេញសិទ្ធិតាំងពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ មានអត្តលេខ៧៩២ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាហើយកំពុងប្រកបវិជ្ជាជីវៈមេធាវីនៅការិយាល័យមេធាវី អេច អិល (HL LAW office ) ។ក្នុងគោលបំណងរួមចំណែកពង្រឹងនិងលើកស្ទួយវិជ្ជាជីវៈមេធាវី ខ្ញុំបានពិតជាមានពេលវេលាគ្រប់គ្រាន់ និងឆន្ទៈក្នុងការជួយបំរើការងារនៅក្នុងនាយកដ្ឋានអធិការកិច្ចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមការចាត់តាំងរបស់ប្រធានគណៈមេធាវីឬប្រធាននាយកដ្ឋានអធិការកិច្ច។

អាស្រ័យដូចបានជំរាបជូនខាងលើសូម **លោកប្រធាន** មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

សូម**លោកប្រធាន**មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ភ្នំពេញ.ថ្ងៃទី២០ខែមករា ឆ្នាំ២០១៦

**ហត្ថលេខានិងត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី. សេង_ឈុនលី

21/01/16

ប៊ុន ណាវីណា

22.01.2016

មេធាវី.ប៊ុន_ហុន